**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប**
**ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**
**លេខាធិការដ្ឋាន**

លេខ ០៣០ សជណ /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១១

**សូមជម្រាបជូន**

**ឯកឧត្តម អភិបាលរាជធានីភ្នំពេញ និងអភិបាលគ្រប់ខេត្ត**

**<u>កម្មវត្ថុ</u>** : ស្តីពីការរៀបចំសមាសភាពសមាជិក និង/ឬសមាជិកអចិន្ត្រៃយ៍នៃក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

**<u>យោង</u>** : សេចក្តីណែនាំលេខ ០០៣ សណន /គ.ជ.អ.ប ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១១ របស់លេខាធិការដ្ឋាន គ.ជ.អ.ប ស្តីពីការបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបមកឯកឧត្តមជ្រាបថា : ដើម្បីជួយគាំទ្រដល់ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តឱ្យបានទាន់ពេលវេលាស្របតាមលិខិតបទដ្ឋានកំណត់ លេខាធិការដ្ឋាន គ.ជ.អ.ប បានធ្វើការណែនាំដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឱ្យបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលមានសមាសភាព និងតួនាទី ភារកិច្ច ដូចបានកំណត់នៅក្នុងសេចក្តីណែនាំយោងខាងលើ ។

ទាក់ទិននឹងការរៀបចំសមាសភាពក្រុមការងារខាងលើនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានពិនិត្យឃើញថាមានក្រុង ស្រុក ខណ្ឌមួយចំនួន នៅតែពុំអាចដំណើរការបង្កើតក្រុមការងារនេះបាននៅឡើយ ដោយហេតុថា ពុំមានសមាសភាពសមាជិកមួយចំនួនដូចជា នាយករដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រធានការិយាល័យផែនការ ស្ថិតិ ឬការិយាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំជាសមាជិក និង/ឬ សមាជិកអចិន្ត្រៃយ៍នៃក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

ដើម្បីឱ្យដំណើរការរៀបចំបង្កើតក្រុមការងារនេះ អាចដំណើរការទៅបាននៅគ្រប់ក្រុង ស្រុក ខណ្ឌ លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំបន្ថែម ដូចខាងក្រោម :

១- ចំពោះក្រុង ស្រុក ខណ្ឌ ដែលពុំមានសមាសភាពនាយករដ្ឋបាល ឬ ប្រធានការិយាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬការិយាល័យជំនាញណាមួយ ដែលត្រូវរៀបចំជាសមាជិកក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំនោះ រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ អាចបង្កើតក្រុមការងារនេះបាន ដោយពុំចាំបាច់មានសមាសភាពសមាជិក ដូចបានកំណត់នៅក្នុងសេចក្តីណែនាំខាងលើ ។ ប៉ុន្តែនៅពេលសមាសភាពដែលទំនេរខាងលើ

ត្រូវបានរៀបចំនៅតាមសាលាក្រុង ស្រុក ខណ្ឌនីមួយៗរួចហើយ ក្រុមប្រឹក្សាអាចពិនិត្យ សម្រេចបញ្ចូលបន្ថែមសមាសភាព ទាំងនេះ ទៅក្នុងក្រុមការងារឱ្យបានស្របទៅតាមគោលការណ៍កំណត់ ។ ក្រោយពីក្រុមប្រឹក្សាពិនិត្យ ឯកភាពទៅលើការកែសម្រួលសមាសភាពក្រុមការងារនេះរួចហើយ អភិបាលក្រុង ស្រុក ខណ្ឌ **ត្រូវចេញសេចក្ដីសម្រេចបន្ថែមសមាសភាព** សមាជិកក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ខ្លួន ។

២- ដោយឡែក ក្នុងករណីដែលក្រុង ស្រុក ខណ្ឌណា ដែលពុំមានសមាសភាព**ប្រធានការិយាល័យផែនការ ស្ថិតិ** ដើម្បីរៀបចំជា**សមាជិកអចិន្ត្រៃយ៍** ក្រុមប្រឹក្សាអាចជ្រើសរើសសមាសភាពអនុប្រធានការិយាល័យផែនការ ស្ថិតិក្រុង ស្រុក ខណ្ឌ មកជំនួសបាន ។ ប្រសិនបើ ពុំមានសមាសភាពអនុប្រធានការិយាល័យផែនការ ស្ថិតិក្រុង ស្រុក ខណ្ឌ ទៀតនោះ ក្រុមប្រឹក្សាត្រូវជ្រើសរើសប្រធាន ឬអនុប្រធានការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់របស់សាលាស្រុក ឬការិយាល័យផែនការ និងគាំទ្រសង្កាត់របស់សាលាក្រុង ឬការិយាល័យផែនការ និងអភិវឌ្ឍន៍របស់សាលាខណ្ឌ ដើម្បីរៀបចំជាសមាជិកអចិន្ត្រៃយ៍នៃក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តម ទទួលនូវសេចក្ដីរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**រដ្ឋលេខាធិការ និងជា**

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

សក់_សេដ្ឋា

**ចម្លងជូន ៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ឯកសារ - កាលប្បវត្តិ